ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ: ០៨៧ MIH / 2016

# ប្រកាស
# ស្តីពី
# ការបង្កើតការិយាល័យផលិតកម្មស្អាតចំណុះមជ្ឈមណ្ឌលផលិតភាពជាតិ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង-ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ៤៣៤ MIH/2014 ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលផលិតភាពជាតិ
- លិខិតលេខ ១២៧ មស.នក ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៦ របស់ក្រសួងមុខងារសាធារណៈ
- លិខិតលេខ ១០៧១ សហវ.អថ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ១.-**

បង្កើតការិយាល័យផលិតកម្មស្អាត ស្ថិតក្រោមរចនាសម្ព័ន្ធគ្រប់គ្រងរបស់មជ្ឈមណ្ឌលផលិតភាពជាតិនៃអគ្គនាយកដ្ឋានឧស្សាហកម្ម ដោយបំពេញបន្ថែមលើប្រកាសលេខ ៤៣៤ MIH/2014 ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលផលិតភាពជាតិ។

**ប្រការ២.-**

ការិយាល័យផលិតកម្មស្អាតមានតួនាទី និងភារកិច្ចដូចខាងក្រោម៖



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣ ២១១ ៨៩៤
អ៊ីមែល: mih.smcabinet@gmail.com

ក- តួនាទី

ការិយាល័យផលិតកម្មស្អាត ជាសេនាធិការឱ្យថ្នាក់ដឹកនាំមជ្ឈមណ្ឌលផលិតភាពជាតិ លើការងារផលិតកម្មស្អាត ដើម្បីអភិវឌ្ឍន៍វិស័យឧស្សាហកម្ម និងសិប្បកម្ម ប្រកបដោយនិរន្តរភាព។

ខ- ភារកិច្ច

ការិយាល័យផលិតកម្មស្អាត មានភារកិច្ចដូចតទៅ៖

- ផ្សព្វផ្សាយអំពីគោលគំនិតរបស់ផលិតកម្មស្អាតដល់ម្ចាស់រោងចក្រ សហគ្រាសទាំងអស់ ដើម្បីឱ្យយល់ដឹងអំពីដំណើរការប្រតិបត្តិការរោងចក្រ សហគ្រាសរបស់ខ្លួន ក្នុងការកាត់បន្ថយសំណល់ការកែច្នៃឡើងវិញ និងការកែប្រែផលិតផល ក្នុងគោលបំណងបង្កើនប្រសិទ្ធភាពសេដ្ឋកិច្ច ជួយការពារបរិស្ថាន និងសង្គមប្រកបដោយចីរភាព
- បណ្តុះបណ្តាលធនធានមនុស្សទាំងក្នុងស្ថាប័នរដ្ឋ និងវិស័យឯកជនឱ្យយល់ដឹងអំពីផលិតកម្មស្អាត
- សហការជាមួយស្ថាប័នរដ្ឋ សហគ្រាស វិស័យឯកជន និងដៃគូអភិវឌ្ឍន៍នានា ក្នុងការផ្តល់សេវាពិគ្រោះយោបល់លើកម្មវិធីផលិតកម្មស្អាត និង
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតដែលប្រធានមជ្ឈមណ្ឌលផលិតភាពជាតិប្រគល់ជូន។

**ប្រការ៣.-**

ការិយាល័យផលិតកម្មស្អាត ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជាជំនួយការដោយអនុលោមតាមអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

**ប្រការ៤.-**

ការបែងចែកភារកិច្ចរបស់មន្ត្រីការិយាល័យផលិតកម្មស្អាត ជាសមត្ថកិច្ចរបស់ប្រធានមជ្ឈមណ្ឌលផលិតភាពជាតិ។

**ប្រការ៥.-**

រចនាសម្ព័ន្ធគ្រប់គ្រងរបស់មជ្ឈមណ្ឌលផលិតភាពជាតិ ដែលបានកំណត់ក្នុងប្រកាសលេខ ៤៣៤ MIH/2014 ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលផលិតភាពជាតិ ត្រូវបានកែសម្រួលដូចមានឧបសម្ព័ន្ធភ្ជាប់ជាមួយប្រកាសនេះ។

**ប្រការ៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៧.-**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានវិទ្យាស្ថាន ប្រធានមជ្ឈមណ្ឌល ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ ប្រធានមជ្ឈមណ្ឌលផលិតភាពជាតិ និងគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង ត្រូវអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែមីនា ឆ្នាំ២០១៦

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ចម ប្រសិទ្ធ**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- សាលារាជធានី ខេត្ត
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ